# អនុស្សរណៈនៃការយោគយល់

## រវាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៃព្រះរាជាណាចក្រកម្ពុជា និងសាជីវកម្មថាមពលបរមាណូរដ្ឋ «ROSATOM» (សហព័ន្ធរុស្ស៊ី) ស្តីពីការបង្កើតមជ្ឈមណ្ឌលព័ត៌មានថាមពលនុយក្លេអ៊ែរ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនៃព្រះរាជាណាចក្រកម្ពុជា និងសាជីវកម្មថាមពលបរមាណូរដ្ឋ «ROSATOM» (សហព័ន្ធរុស្ស៊ី) ចាប់ពីពេលនេះតទៅ ត្រូវបានហៅកាត់ដោយឡែកពីគ្នាថា «ភាគី» និងហៅរួមគ្នាថា «គូភាគី»

**ដោយអនុលោមតាម** អនុស្សរណៈនៃការយោគយល់ រវាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនៃព្រះរាជាណាចក្រកម្ពុជា និងសាជីវកម្មថាមពលបរមាណូរដ្ឋ «ROSATOM» (សហព័ន្ធរុស្ស៊ី) ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៥ និង

**ដោយទទួលស្គាល់** អំពីសារៈសំខាន់នៃការយល់ដឹងជាសាធារណៈក្នុងចំណោមប្រជាជនកម្ពុជា ស្តីពីគោលការណ៍ដំណើរការឧស្សាហកម្មនុយក្លេអ៊ែរ សុវត្ថិភាពនៃសារធាតុនុយក្លេអ៊ែរនិងការសាយភាយវិទ្យុសកម្ម ការប្រើប្រាស់និងទស្សនវិស័យចំពោះការអភិវឌ្ឍថាមពលនុយក្លេអ៊ែរនិងឧស្សាហកម្មនុយក្លេអ៊ែរនៅកម្ពុជា និងអំពីភាពចាំបាច់ក្នុងការបង្កើនជំនឿទុកចិត្តដល់យុវជនជំនាន់ក្រោយលើការប្រកបមុខរបរក្នុងវិស័យឧស្សាហកម្ម

**បានសម្រេចនូវការយោគយល់គ្នាដូចខាងក្រោម៖**

គូភាគីមានបំណងរួមគ្នាបង្កើត **មជ្ឈមណ្ឌលព័ត៌មានថាមពលនុយក្លេអ៊ែរ** (ដែលហៅកាត់ថា "មជ្ឈមណ្ឌលព័ត៌មាន") នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។

គូភាគីមានបំណងសហការរៀបចំសកម្មភាពរួមគ្នា ដើម្បីលើកកម្ពស់ការយល់ដឹងដល់ប្រជាជនកម្ពុជាអំពីការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព សុវត្ថិភាពនៃសារធាតុនុយក្លេអ៊ែរនិងការសាយភាយវិទ្យុសកម្ម និងបញ្ហាពាក់ព័ន្ធដទៃទៀត តាមរយៈការប្រើប្រាស់ទីតាំងមជ្ឈមណ្ឌលព័ត៌មាន ដោយមិនគិតថ្លៃ។

គូភាគីមានបំណងស្វែងរកគ្រប់មធ្យោបាយលើកទឹកចិត្តនូវរាល់គំនិតផ្តួចផ្តើម និងការអនុវត្តគម្រោងនានា សំដៅគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្មនុយក្លេអ៊ែរនៃព្រះរាជាណាចក្រកម្ពុជា។

គូភាគីមានបំណងអនុវត្តរួមគ្នានូវរាល់កម្មវិធីសហប្រតិបត្តិការជាមួយក្រសួងស្ថាប័នរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានីតិបុគ្គលគ្រប់

ប្រភេទ ដោយរាប់បញ្ចូលទាំងគ្រឹះស្ថានសាធារណៈ។ រាល់សកម្មភាពត្រូវមានទិសដៅជំរុញលើកទឹកចិត្តឱ្យយុវជនងាកទៅរកការសិក្សាផ្នែកបច្ចេកទេស។

ភាគីរុស្ស៊ីមានបំណងគាំទ្រនិងជួយដល់ការបង្កើតមជ្ឈមណ្ឌលព័ត៌មាន និងការអភិវឌ្ឍក្របខ័ណ្ឌផ្នែកព័ត៌មាន វិទ្យាសាស្ត្រ និងវិធីសាស្ត្រ សំដៅលើកកម្ពស់ការយល់ដឹងសាធារណៈដល់ប្រជាជនគ្រប់មជ្ឈដ្ឋាន ជាពិសេសក្នុងជួរសិស្សានុសិស្ស និងយុវជនពាក់ព័ន្ធនឹងការយល់ដឹងអំពីគោលការណ៍ដំណើរការឧស្សាហកម្មនុយក្លេអ៊ែរ ការប្រើប្រាស់សមិទ្ធផលផ្នែកវិទ្យាសាស្ត្រនុយក្លេអ៊ែរដោយសន្តិវិធី សុវត្ថិភាពនៃសារធាតុនុយក្លេអ៊ែរនិងការសាយភាយវិទ្យុសកម្ម ការប្រើប្រាស់និងទស្សនវិស័យចំពោះការអភិវឌ្ឍថាមពលនុយក្លេអ៊ែរនិងឧស្សហកម្មនុយក្លេអ៊ែរនៅកម្ពុជា ក៏ដូចជាការជំរុញឱ្យមានការទទួលស្គាល់ជាសាធារណៈក្នុងដំហរវិជ្ជមានចំពោះឧស្សាហកម្មថាមពលនុយក្លេអ៊ែរជារួម។

ភាគីកម្ពុជាមានបំណងចូលរួមចំណែកតាមលទ្ធភាព និងសមត្ថកិច្ចរបស់ខ្លួនក្នុងការជ្រើសរើសទីតាំងសម្រាប់មជ្ឈមណ្ឌលព័ត៌មាន និងបេក្ខជននាយកមជ្ឈមណ្ឌលព័ត៌មាន ព្រមទាំងរៀបចំចងក្រងកែសម្រួល សៀវភៅការងារ និងសម្ភារៈឧបទេសសិក្សានិងព័ត៌មានឱ្យបានទាន់ពេលវេលា ដែលមានភាពចាំបាច់សម្រាប់ទ្រទ្រង់ដល់ប្រតិបត្តិការមជ្ឈមណ្ឌលព័ត៌មាន។

គូភាគីមានបំណងពិភាក្សាលើការងារហិរញ្ញវត្ថុនៃកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងការរៀបចំ និងអនុវត្តកម្មវិធី គម្រោង និងពិធីនានា សំដៅលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការទទួលស្គាល់នូវថាមពលនុយក្លេអ៊ែរ និងលទ្ធភាពអាចអភិវឌ្ឍថាមពលនុយក្លេអ៊ែរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយតម្រូវឱ្យមានការពិគ្រោះយោបល់បន្ថែម។

គូភាគីមានបំណងធ្វើកិច្ចសហប្រតិបត្តិការតាមរយៈ៖

- ការរៀបចំពិធីរួមគ្នា (កម្មវិធី និងសកម្មភាព) ទៅតាមសមត្ថភាពរបស់គូភាគីក្នុងផ្នែកវិទ្យាសាស្ត្រ ព័ត៌មាន ផលិតកម្ម និងការធ្វើពិសោធន៍
- ការផ្លាស់ប្តូរព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកទេស និងលទ្ធផលនៃការសិក្សាស្រាវជ្រាវ
- ការចូលរួមក្នុងការតាំងពិព័រណ៍ ពិព័រណ៍ពាណិជ្ជកម្ម សន្និសីទ វេទិកា និងពិធីផ្សេងៗ
- ការសហការរៀបចំ និងចែកចាយសម្ភារៈឧបទេសព័ត៌មាននិងឯកសារពិគ្រោះ គោលការណ៍ណែនាំវិធីសាស្ត្រ និងសេចក្តីព្រាងបទប្បញ្ញត្តិនានា និង

- ទម្រង់ជាច្រើនផ្សេងទៀតនៃកិច្ចសហប្រតិបត្តិការ ដែលមិនមានលក្ខណៈផ្ទុយនឹងច្បាប់រដ្ឋាភិបាលរបស់គូភាគី អាចត្រូវបានរៀបចំឡើងនិងអនុម័តដោយគូភាគី។

រាល់វិវាទដែលកើតចេញពីការបកស្រាយឬការអនុវត្តអនុស្សរណៈនៃការយោគយល់នេះ ត្រូវដោះស្រាយដោយការពិគ្រោះយោបល់រវាងគូភាគី។

អនុស្សរណៈនៃការយោគយល់នេះមិនមែនជាសន្ធិសញ្ញាអន្តរជាតិ និងមិនមានចែងអំពីសិទ្ធិ និងកាតព្វកិច្ចណាមួយ ដែលកំណត់ដោយច្បាប់អន្តរជាតិ ឬច្បាប់ជាតិឡើយ។ អនុស្សរណៈនៃការយោគយល់នេះអាចត្រូវបានកែសម្រួល ដោយការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សររវាងគូភាគី។

អនុស្សរណៈនៃការយោគយល់នេះ ត្រូវបានចុះសម្រាប់រយៈពេលមិនកំណត់ និងត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាដោយគូភាគី។ ភាគីនីមួយៗអាចបញ្ចប់អនុស្សរណៈនៃការយោគយល់នេះ ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតឱ្យបានយ៉ាងហោចបីខែ នៅមុនកាលបរិច្ឆេទដែលភាគីណាមួយមានបំណងចង់បញ្ចប់។

ការបញ្ចប់អនុស្សរណៈនៃការយោគយល់នេះនឹងមិនប៉ះពាល់ដល់ដំណើរការអនុវត្តគម្រោង កម្មវិធី និងសកម្មភាពនានា ដែលត្រូវបានព្រមព្រៀងដោយគូភាគីឡើយ។

អនុស្សរណៈនៃការយោគយល់នេះ ត្រូវបានចុះហត្ថលេខានៅទីក្រុងម៉ូស្គូនៃសហព័ន្ធរុស្ស៊ី នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ធ្វើឡើងចំនួនពីរច្បាប់ ដោយច្បាប់នីមួយៗមានជាភាសាខ្មែរ ភាសារុស្ស៊ី និងភាសាអង់គ្លេស។ ក្នុងករណីមានការបកស្រាយផ្សេងៗពីគ្នា នោះសំណៅជាភាសាអង់គ្លេសនឹងត្រូវប្រើជាឯកសារគោល៕

| | |
|---|---|
| **តំណាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៃព្រះរាជាណាចក្រកម្ពុជា** | **តំណាងសាជីវកម្មថាមពលបរមាណូរដ្ឋ «ROSATOM» (សហព័ន្ធរុស្ស៊ី)** |
| **សាយ សំអាល់** | **សៀរហ្គាយ គីរៀនកូ** |

**MEMORANDUM OF UNDERSTANDING**

BETWEEN THE NATIONAL COUNCIL FOR SUSTAINABLE DEVELOPMENT OF THE KINGDOM OF CAMBODIA AND THE STATE ATOMIC ENERGY CORPORATION "ROSATOM" (THE RUSSIAN FEDERATION) ON THE ESTABLISHMENT OF INFORMATION CENTRE OF NUCLEAR ENERGY

The National Council for Sustainable Development of the Kingdom of Cambodia and the State Atomic Energy Corporation "Rosatom" (the Russian Federation), hereinafter referred to singularly as "the Party" and collectively as "the Parties",

In accordance with the Memorandum of Understanding between the National Council for Sustainable Development of the Kingdom of Cambodia and the State Atomic Agency Corporation "Rosatom" (the Russian Federation) on Cooperation in the Use of Atomic Energy for Peaceful Purposes of 24 November 2015 and

Recognizing the importance of public awareness among the Cambodian people on nuclear industry performance principles, nuclear and radiation safety, issues and perspectives of nuclear energy and nuclear industry development in Cambodia, and of the need to increase the credibility of industrial occupations among the younger generation,

**Have reached the common understanding on the following**:

The Parties intend to join their efforts on the establishment of Information Centre of Nuclear Energy (referred to as Information Centre) in Phnom Penh, the Kingdom of Cambodia.

The Parties intend to facilitate collaboration in the field of arranging joint awareness-raising activities with the Cambodian people relating to nuclear energy for peaceful purposes, nuclear and radiation safety, and other related issues within the premises of Information Centre and on a free-of-charge basis.

The Parties are willing to explore the ways of encouraging the initiation and implementation of projects intended for the development of the nuclear industry of the Kingdom of Cambodia.

The Parties intend to implement programs of cooperation jointly with the governmental agencies and local authorities of the Kingdom of Cambodia as well as legal entities of the various forms of property, including public organizations. The activities would aim at encouraging the young people towards technical education.

The Russian Party intends to support and assist the establishment of Information Centre and the development of informational, scientific and methodological framework with a view to raise the level of public awareness of various groups of population, primarily school children's and young people's awareness on nuclear industry and nuclear energy performance principles, peaceful use of nuclear science achievements, nuclear and radiation safety, issues and perspectives of nuclear energy and nuclear industry development in the Kingdom of Cambodia, as well as to develop persistent positive public acceptance of the nuclear energy industry in general.

The Cambodian Party intends to render all needed assistance, within its capacity and mandate, in selecting premises for the Information Centre, the candidate for the Centre's director as well as to harmonize on a timely basis workbooks, educational and informational materials required for the Information Centre's operation.

The Parties intend to discuss the financial aspects of the cooperation related to the development and implementation of the public awareness raising programs, projects and events with the purpose of increasing the public awareness on and acceptance of nuclear energy and the prospects of its development in the Kingdom of Cambodia in course of further consultations.

The Parties intend to cooperate by way of:

- joint events (programs, works) with the use of scientific, informational, production and experimental capacities of the Parties;
- mutual exchange of the scientific and technical information and the results of research work;

- participation in the exhibitions, trade fairs, conferences, forums and other events;
- in collaboration with each other development and release of the informational and reference materials, methodological guidelines, drafts of the regulatory acts; and
- other forms of cooperation which are not contrary to the laws of the governments of the Parties intended to achieve the goals and approved by all Parties.

Any dispute arising in the interpretation or implementation of this Memorandum will be settled through consultations between the Parties.

This Memorandum is not an international treaty and does not set any rights and obligations, regulated by international or national law. The Memorandum may be amended by the mutual written consent of the Parties.

This Memorandum is concluded for indefinite period of time and is applied from the date of signature by the Parties. Each Party may terminate this Memorandum by giving a written notice to the other Party at least three months prior to the intended date of the termination.

The termination of this Memorandum will not affect any ongoing projects, programs and activities which have been agreed by the Parties.

This Memorandum is signed in Moscow, the Russian Federation, 17 day of May 2016, in duplicate, each in Khmer, Russian and English languages. In case of divergences, the English text shall be used.

| | |
|---|---|
| **For the National Council for Sustainable Development of the Kingdom of Cambodia** | **For the State Atomic Energy Corporation "Rosatom" (the Russian Federation)** |
| **SAY SAMAL** | **SERGEY KIRIENKO** |